# ព្រះរាជក្រឹត្យ

នស/រកត/០៥០៤/០៧០

## ស្តីពី
## ការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ

*****

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០០៤

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទកោះកែរ ជារមណីយដ្ឋានការពារ ស្ថិតក្នុងឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និងលើកកម្ពស់តំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថានធម្មជាតិក្នុងតំបន់ តាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ។

## ជំពូកទី ២

## ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទកោះកេរត្រូវចាត់ជា ៣ ( បី ) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកិរិតការពារខុសៗគ្នា :

១- តំបន់ស្នូល : ជាតំបន់ដែលមានប្រាសាទធំ ហៅថាតំបន់ " ក " និងរហាល ហៅថាតំបន់ " ខ " ។

តំបន់ទាំង២ ( ពីរ ) ត្រូវបានកំណត់ដូចខាងក្រោមនេះ :

តំបន់ ក : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A1 ( 450190 ; 1523180 ) , A2( 450100 ; 1523620 )
A3 ( 450730 ; 1523730 ) , A4( 450790 ; 1523280 )

តំបន់ ខ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

B1 ( 450710 ; 1523226 ) , B2 ( 451245 ; 1523343 )
B3 ( 451608 ; 1522253 ) , B4 ( 451071 ; 1522106 )

តំបន់ស្នូលនេះ មានផ្ទៃក្រលាសរុប ៩២ ហិកតា ៦២ អារ ( កៅសិបពីរ ហិកតា ហុកសិបពីរ អារ ) ។

តំបន់ " ក " និង " ខ " ជារមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកិរិតខ្ពស់បំផុត ។

២- តំបន់ទ្រនាប : ជាតំបន់ឧទ្យានបុរាណវិទ្យា សម្បូរដោយប្រាសាទតូចៗ និងសំណល់បុរាណវត្ថុជាច្រើនដែលបានបន្សល់ទុកនូវដាន ស្នាកស្នាម ឬកប់ក្នុងដី រាក់ឬជ្រៅនៅតាមទីវាល ព្រៃឈើជាដើម ហើយដែលអ្នកបុរាណវិទ្យា បានរកឃើញ និងពុំទាន់រុករកឃើញនៅឡើយ ។

តំបន់នេះមានផ្ទៃក្រឡា ៣.៥០៧ ហិកតា ៦៣អារ ( បីពាន់ប្រាំរយប្រាំពីរហិកតា និងហុកសិបបីអារ ) ។

តំបន់នេះស្ថិតនៅក្រៅបរិវេណតំបន់ " ក " និងតំបន់ " ខ " នៃតំបន់ស្នូលហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច :

C ( 448000 ; 1526000 ) , D ( 448000 ; 1520000 )
E ( 454000 ; 1520000 ) , F ( 454000 ; 1526000 )

តំបន់នេះសម្បូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍មិនសមស្រប ។

៣- តំបន់រណប : ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរអាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច C D E F ចម្ងាយ ១.៥០០ម៉ែត្រ ( មួយពាន់ប្រាំរយ ម៉ែត្រ ) ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍន៍ឱ្យមាននិរន្តរភាព និងមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សរាល់តំបន់នីមួយៗសុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និងកិតនៃសារៈសំខាន់ដោយឡែកៗទាំងខាង បូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ទ្រព្យសម្បត្តិធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំនិងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទទួលអនុវត្តផ្ទាល់ ដោយផ្អែកលើមាត្រា ៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទនិងនីតិវិធីនៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានប្រាសាទកោះកែរ ក្នុងបណ្តាមាត្រាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ការកែប្រែតំបន់

**មាត្រា ៧.-**

បរិវេណ និងរាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទកោះកែរ អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែតំបន់ និងរាល់សកម្មភាពពាក់ព័ន្ធនិងរមណីយដ្ឋានប្រាសាទកោះកែរ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា និងព្រះរាជលញ្ឆករ

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ពរស.០៤.០៥.០៧០

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

លេខៈ ៥៧ . ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**